ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ៩៥៦ អក

ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២

សាលក្រមនៃបណ្តឹងទាស់

លេខៈ ០៧៨ "ណ"

ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**

តុលាការខេត្តកណ្តាល បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ ដោយមានសមាសភាពដូចតទៅៈ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជី

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៩ "ណ" ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៣ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៩៥៦ អក ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ដែលមានជនជាប់ចោទឈ្មោះ [redacted] លាងហេង ភេទប្រុស អាយុ ២០ ឆ្នាំ (កើតឆ្នាំ ១៩៩០) ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] លន (រស់) ម្តាយឈ្មោះ [redacted] គី (រស់) នៅលីវ ទោសពីមុនគ្មាន ។

ជាប់ចោទពីបទៈ ហឹង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចំការដូង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ ២០១២ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

ដែលមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ឈ្មោះ [redacted] លាងហេង ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារុំ ភេទស្រី អាយុ៤៩ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតដូចនិងទីលំនៅបច្ចុប្បន្ននៅភូមិទូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] ប៊ិន (រស់) ប្តីឈ្មោះ [redacted] គ្រេង ទោសពីមុនគ្មាន។

ជនរងគ្រោះឈ្មោះ [redacted] ខ្លឹង ភេទប្រុស អាយុ ៣៩ឆ្នាំ ទីកន្លែងកំណើតដូចនិងទីលំនៅបច្ចុប្បន្ននៅភូមិទួលស្វាយ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល មុខរបរ កសិករ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] ប៊ិន (រស់) ប្រពន្ធឈ្មោះ [redacted] ខេង មានកូន ០៣ នាក់ ទោសពីមុនគ្មាន ។

*អង្គហេតុនៃរឿងមានដូចតទៅៈ*

កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ ប្រហែលម៉ោង ២៣ ឈ្មោះ [redacted] ខ្លឹង ,ឈ្មោះ [redacted] តេង និងឈ្មោះ [redacted] ចន្ទី មានពិធីជួបជុំផឹកស៊ីនៅផ្ទះឈ្មោះ នាង ក្រោយពីផឹកស្រាអស់ពួកគេបាននាំគ្នាជិះម៉ូតូទៅទិញស្រាចំនួន ០២ (ពីរ) លីត្រ បន្ថែមទៀត ក្រោយពីទិញស្រាបានហើយ ពួកគេនាំគ្នាចូលទៅផឹកកាហ្វេ ពេលនោះពួក

គេបានជួបនិងមនុស្សពីរបីនាក់ផ្សេងទៀត ដែលកំពុងនាំគ្នាផឹកស្រានៅក្នុងរោងកាហ្វេនោះ ហើយឈ្មោះ [redacted] តេង ស្គាល់ឈ្មោះ ឌីណា ហៅ ស្វា កំពុងអង្គុយផឹកនៅក្នុងរោងកាហ្វេនោះដែរ ពេលនោះឈ្មោះ ឌីណា ហៅ ស្វា បានបបួលឈ្មោះ [redacted] ខ្លឹង ,ឈ្មោះ [redacted] តេង និងឈ្មោះ [redacted] ចន្ទី ផឹកជាមួយពួកនោះចូលផឹកជាមួយគ្នាបានមួយសន្ទុះក្រុមរបស់ឈ្មោះ ឌីណា ហៅ ស្វា ជិះម៉ូតូចេញទៅមុនបាត់ចំណែកក្រុមរបស់ឈ្មោះ [redacted] ខ្លឹង នាំគ្នាជិះម៉ូតូចេញទៅតាមក្រោយ បន្ទាប់មកក្រុមរបស់ឈ្មោះ [redacted] ខ្លឹង នេះត្រូវក្រុមរបស់ឈ្មោះ [redacted] ឌីណា ហៅ ស្វា ស្ទាក់វាយដោយដំបងនៅតាមផ្លូវ ពេលម៉ូតូរបស់ក្រុមឈ្មោះ [redacted] ខ្លឹង ដួលម៉ូតូនោះបានចាំងភ្លើងទៅលើក្រុម ឌីណា ហៅ ស្វា ហើយឈ្មោះ [redacted] តេង បានមើលឃើញឈ្មោះ [redacted] គឹមឡេង ហៅ ផ្លយ កំពុងប្រតាយប្រតប់និងឈ្មោះ [redacted] ខ្លឹង និងដំបងចំណែកឈ្មោះ [redacted] ចន្ទី ក៏ត្រូវបានឈ្មោះ [redacted] ឌីណា ហៅ ស្វា វាយឲ្យរបួសនិងដំបងដែរ ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៥៩៦ ដកសស ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣០៦ ដកសព ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះបន្ត លេខ ៦២២ ដកសរជរ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

## នាពេលសវនាការ

១. ជនជាប់ចោទឈ្មោះ [redacted] ឈាងហេង បានឆ្លើយថា: ចំពោះការចោទប្រកាន់របស់តុលាការលើរូបខ្លួនពាក់ព័ន្ធនឹងបទល្មើស ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចំការដូង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ នោះខ្លួនមិនបានដឹងទេ ហើយខ្លួនក៏មិនបានស្នាក់នៅស្រុកកំណើតដែរ ខ្លួនបានទៅប្រកបរបរលក់ចេកអាំងនៅឯរាជធានីភ្នំពេញ ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] គឹមឡេង ឈ្មោះ [redacted] សុខនី និងឈ្មោះ [redacted] ឌីណា ទេ ។ ទើបតែថ្មីៗនេះ ខ្លួនបានទទួលដំណឹងអំពីសាលក្រមព្រហ្មទណ្ឌលេខ ២៩ "ណ"ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៣ សំណុំរឿងព្រហ្មទណ្ឌលេខ: ៩៥៦ អក ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ផ្តន្ទាទោសលើខ្លួនដោយដាក់ពន្ធនាគារចំនួន ០២ (ពីរ) ឆ្នាំ ទើបខ្លួនដាក់ពាក្យបណ្តឹងទាស់លើសាលក្រមនេះទាំងស្រុងតែម្តង ។

២. អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារុំ បានឆ្លើយបំភ្លឺថា: នៅថ្ងៃកើតហេតុប្រហែលម៉ោង ១១យប់ ត្រូវនឹងថ្ងៃ០៣ ខែធ្នូ ឆ្នាំ២០១២ មានអ្នកភូមិប្រហែល ១០នាក់ បានមកប្រាប់ខ្លួនថាប្អូនប្រុសខ្លួនឈ្មោះ [redacted] ខ្លឹង ត្រូវគេវាយសន្លប់ឮដំណឹងនេះភ្លាមខ្លួនរត់ទៅមើលប្អូននៅកន្លែងកើតហេតុ និងបានយក ប្អូនប្រុសទៅព្យាបាលរបួលនៅមន្ទីរពេទ្យ តែខ្លួនមិនបានដឹងថាប្អូនប្រុសខ្លួនរងរបួលត្រង់ណាទេ ព្រោះយប់ងងឹងពេក ក្នុងរឿងនេះខ្លួនសុំទាមទារថ្លៃព្យាបាល និងជម្ងឺចិត្តប្រាក់ចំនួន ៣០០០$ (បីពាន់ដុល្លារអាមេរិក) និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

៣. អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ខ្លឹង បានឆ្លើយបំភ្លឺថា: កាលពីថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០១២ ប្រហែលម៉ោង ២៣ ខ្លួនបានជិះម៉ូតូជាមួយឈ្មោះ ធួក ចូលទៅផឹកស្រានៅផ្ទះឈ្មោះ ឃៀង ខ្លួនអង្គុយផឹកបានមួយសន្ទុះក្មួយប្រុសខ្លួនឈ្មោះ [redacted] តេង ឌុបខ្លួនទៅផ្ទះពេលនោះឈ្មោះ ចន្ទី ក៏ជិះម៉ូតូទៅជាមួយខ្លួនដែរ បន្ទាប់មកពួកខ្លួននាំគ្នាឈប់ម៉ូតូផឹកកាហ្វេនៅផ្ទះឈ្មោះ រ៉ានី ហៅយាយ សេះ តែអ្នកលក់ប្រាប់ថាអស់កាហ្វេហើយ ពេលនោះខ្លួនឃើញមានមនុស្សប្រុសចំនួន ០៣ នាក់ កំពុងអង្គុយផឹកស្រានៅក្នុងរោងកាហ្វេនោះហើយពួកគេស្គាល់ក្មួយប្រុសខ្លួនឈ្មោះ [redacted] តេង ពួកគេក៏ហៅពួកខ្លួនឱ្យចូលផឹកស្រាជាមួយពួកគេដែរអ្នកដែលហៅពួកខ្លួននោះគឺឈ្មោះ [redacted] ឌីណា ហៅ ស្វា ចំណែកបក្សពួកគេ ០២ នាក់ទៀតបាននាំគ្នា

ចេញទៅមុន បន្ទាប់មកពួកខ្លួនក៏បានចេញទៅផ្ទះដែរ ពេលពួកខ្លួនធ្វើដំណើរពីរោងកាហ្វេក្មួយប្រុសខ្លួនឈ្មោះ [redacted] គេង ជាអ្នកឌុបខ្លួននិងឈ្មោះ ចន្ទី ពេលពួកខ្លួនធ្វើដំណើរបានបន្តិចស្រាប់តែមានមនុស្សលបវាយពួកខ្លួន ពេលនោះគេវាយត្រូវខ្លួន១ដំបងចំក្បាលបណ្តាលឲ្យខ្លួនធ្លាក់ពីលើម៉ូតូដួលសន្លប់បាត់ស្មារតីនៅកន្លែងកើតហេតុតែម្តង។

៤. អានលិខិតប្តឹងទាស់និងសាលក្រមលេខ ២៩ ណ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកណ្តាល ។

៥. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន: តាមការសួរដេញដោលឃើញថាមិនមានភស្តុតាងដាក់បន្ទុកណាមួយលើជនជាប់ចោទឈ្មោះ [redacted] លាងហេង ក្នុងការប្រព្រឹត្តបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចំការដូង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌនោះទេ ។ ដូច្នេះក្នុងនាមជាតំណាងអយ្យការស្នើសុំឲ្យតុលាការពិចារណា និងសម្រេចឲ្យជនជាប់ចោទឈ្មោះ [redacted] លាងហេង បានរួចខ្លួនពីបទចោទប្រកាន់ បទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចំការដូង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ តាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌផង ។

៦. លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន:

៦.១. តាមអង្គហេតុខាងលើ កូនក្តីរបស់ខ្ញុំឈ្មោះ លន លាងហេង ពុំបានប្រព្រឹត្តអំពើហិង្សាទៅលើជនរងគ្រោះឈ្មោះ ស្រេង ខ្លឹង នោះទេ។

៦.២. ផ្អែកតាមឆ្លើយបំភ្លឺរបស់ជនរងគ្រោះឈ្មោះ [redacted] ខ្លឹង បានឆ្លើយបញ្ជាក់យ៉ាងច្បាស់ថា: ................ផឹកបានមួយសន្ទុះ ឈ្មោះ ឌីណា ហៅ ស្វា និងបក្សពួកបាននាំគ្នាចេញទៅផ្ទះមុន ទើបពួកខ្លួនទៅផ្ទះដែរ ពេលនោះ ក្មួយរបស់ខ្លួនឈ្មោះ [redacted] គេង បានឌុបខ្លួន និងឈ្មោះ ចន្ទី ពេលជិះបានបន្តិច ស្រាប់តែមានជនមិន ស្គាល់ឈ្មោះបានលបវាយមកលើខ្លួនមួយដំបងត្រូវចំក្បាល បណ្តាលឲ្យខ្លួនធ្លាក់ពីលើម៉ូតូដួលសន្លប់បាត់ស្មារតីតែម្តង។

៦.៣. ផ្អែកតាមឆ្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] គេង បានឆ្លើយបំភ្លឺថា: ..............បានមួយសន្ទុះ ខ្លួនក៏បានជិះម៉ូតូចេញពីផ្ទះលក់កាហ្វេនោះដែរ ដោយខ្លួនជាអ្នកឌុប ពូរបស់ខ្លួនជិះកណ្តាល និងឈ្មោះចន្ទី ជិះពីក្រោយ ពេលជិះជិតដល់ភូមិរបស់ខ្លួន ស្រាប់តែមានគេលបវាយពូរបស់ខ្លួន បណ្តាលឲ្យពូរបស់ខ្លួនប្រកាយប្រគប់ ចុះពីលើម៉ូតូធ្វើឲ្យដួលម៉ូតូ ប៉ុន្តែម៉ូតូនៅឆេះបើកភ្លើងដដែល ខ្លួនឃើញឈ្មោះ គឹមឡេង ហៅផ្លុយ ដែលជាបក្សពួក របស់ឈ្មោះ [redacted] ឌីណា ហៅ ស្វា បាននាំគ្នាយកដំបងឈើព្រួតវាយមកលើពូរបស់ខ្លួនឈ្មោះ ខ្លឹង បណ្តាលឲ្យរងរបួសជាទម្ងន់ ពេលនោះ ខ្លួនឃើញបក្សពួករបស់ឈ្មោះ [redacted] ឌីណា និងឈ្មោះ [redacted] គឹមឡេង មានគ្នាទាំងអស់បួននាក់ មានសុទ្ធតែដំបងកាន់ក្នុងដៃពេលនោះ មានម្នាក់កាន់ដំបងដេញវាយខ្លួន ហើយខ្លួនរត់ទៅហៅឲ្យអ្នកភូមិជួយ ចំណែកឯឈ្មោះ ចន្ទី ក៏គេដេញវាយដូចខ្លួនដែរ។

៦.៤. ផ្អែកតាមឆ្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ចន្ទី បានឆ្លើយបំភ្លឺថា:..............ពេលពួកខ្លួនជិះម៉ូតូ ចេញទៅដល់ពាក់កណ្តាលផ្លូវជិតដល់ភូមិ ស្រាប់តែមានមនុស្សលបស្ទាក់វាយមកលើពួកខ្លួន ពេលនោះខ្លួនជិះក្រោយគេ ទើបបានជាគេវាយត្រូវចំនួនមួយដំបង ខ្លួនងាកទៅឃើញឈ្មោះ [redacted] ឌីណា ហៅ ស្វា ជាអ្នកវាយមក លើខ្លួនពីក្រោយចំខ្នង បន្ទាប់មកខ្លួនក៏ស្រវាចុះពីលើម៉ូតូរត់ទៅក្នុងភូមិ ចំណែកឈ្មោះ គ្រេង គេងបានឌុបឈ្មោះ ខ្លឹង ទៅមុខទៀត ខ្លួនមិនបានដឹងថាគេវាយទៅលើឈ្មោះ [redacted] គេង និងឈ្មោះ ខ្លឹង ត្រូវត្រង់



Scanned with CamScanner

ណាខ្លះនោះទេ។

៦.៥. ផ្អែកតាមឆ្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] សុខធិ បានឆ្លើយបំភ្លឺថា:............លុះព្រឹកឡើងថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២ ឈ្មោះ [redacted] សុខនី, ឈ្មោះ [redacted] ឌីណា ហៅ ស្វា និងឈ្មោះ [redacted] លាងហេង បានជូលឲ្យខ្លួនឌុបទៅកំពង់ចម្លងកោះធំ ពេលទៅដល់ពាក់កណ្តាលផ្លូវ ស្រាប់តែឈ្មោះ [redacted] ឌីណា បាននិយាយប្រាប់ខ្លួនថា បានវ៉ៃគេម្នាក់មិនដឹងរស់ ឬស្លាប់ទេយប់មិញ ប៉ុន្តែឈ្មោះ [redacted] ឌីណា មិនបានប្រាប់ថាឈ្មោះអ្វីនោះទេ។

យល់ឃើញថា: ចំពោះអង្គហេតុដែលចោទប្រកាន់ដោយតំណាងអយ្យការ ការឆ្លើយបញ្ជាក់របស់ជនរងគ្រោះ ឈ្មោះ ស្រេង ខ្លឹង និងការឆ្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] គេង, ឈ្មោះ [redacted] ចន្ទី និងឈ្មោះ [redacted] សុខធី អាចបញ្ជាក់បានថា: កូនក្តីរបស់ខ្លួនឈ្មោះ [redacted] លាងហេង ពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ព្រោះពុំមានសាក្សីណាមួយ មកឆ្លើយបញ្ជាក់ឲ្យបានច្បាស់លាស់ថាកូនក្តីខ្លួននៅក្នុងហេតុការណ៍ដែលបានកើតឡើង ឬជាអ្នកប្រព្រឹត្តនោះឡើយ។

យល់ឃើញថា: ដូចអង្គហេតុបានបញ្ជាក់តាមរយៈរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ដីកាសន្និដ្ឋានស្ថាពរ, ដីកាដំណោះស្រាយ, ការរៀបរាប់របស់ជនរងគ្រោះ និងការឆ្លើយបំភ្លឺរបស់សាក្សី គឺពុំបានបញ្ជាក់ឲ្យច្បាស់ពីការប្រព្រឹត្តបទល្មើសរបស់កូនក្តីខ្លួនឡើយ ដែលនាំឲ្យមានវិមតិសង្ស័យលើកូនក្តីខ្លួន និងខ្វះធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ(ធាតុសត្យានុម័ត និងធាតុអត្តនោម័ត)ផងដែរ។

ផ្អែកតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ជនជាប់ចោទ។

ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ [redacted] លាងហេង សូមសំណូមពរឲ្យតុលាការមេត្តាពិចារណា និងសម្រេចដូចខាងក្រោម៖

១/ ឲ្យកូនក្តីរួចខ្លួនពីការចោទប្រកាន់ ពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ នៅចំណុចភូមិចំការផ្លូង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល។

២/ បញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ១៨៥ ដក.បចខ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល។

សេចក្តីដូចបានជម្រាបជូនក្នុងសេចក្តីសន្និដ្ឋានការពារខាងលើនេះ សូមលោកចៅក្រមជំនុំជម្រះមេត្តាពិនិត្យ និងសម្រេចផ្តល់ភាពយុត្តិធម៌ដល់កូនក្តីខ្លួនតាមនីតិវិធិ ដោយក្តីអនុគ្រោះ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
សំដីចុងក្រោយរបស់ជនជាប់ចោទ: សុំឲ្យតុលាការបន្ធូរបន្ថយទោស ។
ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា:**

១. តាមសាលក្រមព្រហ្មទណ្ឌលេខ ២៩ "ណ" ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចទី១.ខ សម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] លាងហេង (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារ កំណត់ រយៈពេល ០២ (ពីរ) ឆ្នាំ ។

ពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចំការដូង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

២. តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] លាងហេង បានឆ្លើយថា:ចំពោះការចោទប្រកាន់របស់តុលាការលើរូបខ្លួនពាក់ព័ន្ធនឹងបទល្មើស ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចំការដូង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ នោះខ្លួនមិនបានដឹងទេ ហើយខ្លួនក៏មិនបានស្នាក់នៅស្រុកកំណើតទេ ខ្លួនបានទៅប្រកបរបរលក់ចេកអាំងនៅឯរាជធានីភ្នំពេញ ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] គឹមឡេង ឈ្មោះ អ៊ុន សុខនិ និងឈ្មោះ [redacted] ឌីណា ទេ ។ ទើបតែថ្មីៗនេះ ខ្លួនបានទទួលដំណឹងអំពីសាលក្រមព្រហ្មទណ្ឌលេខ ២៩ "ណ" ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៣ សំណុំរឿងព្រហ្មទណ្ឌលេខ: ៩៥៦ អក ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ផ្ដន្ទាទោសលើខ្លួនដោយដាក់ពន្ធនាគារចំនួន ០២ (ពីរ) ឆ្នាំ ទើបខ្លួនដាក់ពាក្យបណ្ដឹងទាស់លើសាលក្រមនេះទាំងស្រុងតែម្ដង ។

២. តាមអំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារុំ បានឆ្លើយបំភ្លឺថា: នៅថ្ងៃកើតហេតុប្រហែលម៉ោង ១១យប់ ត្រូវនឹងថ្ងៃ០៣ ខែធ្នូ ឆ្នាំ២០១២ មានអ្នកភូមិប្រហែល ១០នាក់ បានមកប្រាប់ខ្លួនថាប្អូនប្រុសខ្លួនឈ្មោះ [redacted] ខ្លឹង ត្រូវគេវាយសន្លប់ឮដំណឹងនេះភ្លាមខ្លួនរត់ទៅមើលប្អូននៅកន្លែងកើតហេតុ និងបានយក ប្អូនប្រុសទៅព្យាបាលរបួលនៅមន្ទីរពេទ្យ តែខ្លួនមិនបានដឹងថាប្អូនប្រុសខ្លួនរងរបួលត្រង់ណាទេ ព្រោះយប់ងងឹតពេក ក្នុងរឿងនេះខ្លួនសុំទាមទារថ្លៃព្យាបាល និងជម្ងឺចិត្តប្រាក់ចំនួន ៣០០០$ (បីពាន់ដុល្លារអាមេរិក) និងសុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ ។

៣. តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ខ្លឹង បានឆ្លើយបំភ្លឺថា: កាលពីថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០១២ ប្រហែលម៉ោង ២៣ ខ្លួនបានជិះម៉ូតូជាមួយឈ្មោះ ឆ្លក ចូលទៅផឹកស្រានៅផ្ទះឈ្មោះ យៀង ខ្លួនអង្គុយផឹកបានមួយសន្ទុះក្មួយប្រុសខ្លួនឈ្មោះ [redacted] តេង ឌុបខ្លួនទៅផ្ទះពេលនោះឈ្មោះ ចន្ទី ក៏ជិះម៉ូតូទៅជាមួយខ្លួនដែរ បន្ទាប់មកពួកខ្លួននាំគ្នាឈប់ម៉ូតូផឹកកាហ្វេនៅផ្ទះឈ្មោះ រ៉ានី ហៅយាយ សេះ តែអ្នកលក់ប្រាប់ថាអស់កាហ្វេហើយ ពេលនោះខ្លួនឃើញមានមនុស្សប្រុសចំនួន ០៣ នាក់ កំពុងអង្គុយផឹកស្រានៅក្នុងរោងកាហ្វេនោះហើយពួកគេស្គាល់ក្មួយប្រុសខ្លួនឈ្មោះ [redacted] តេង ពួកគេក៏ហៅពួកខ្លួនឱ្យចូលផឹកស្រាជាមួយពួកគេដែរអ្នកដែលហៅពួកខ្លួននោះគឺឈ្មោះ [redacted] ឌីណា ហៅ ស្វា ចំណែកបក្សពួកគេ ០២ នាក់ទៀតបាននាំគ្នាចេញទៅមុន បន្ទាប់មកពួកខ្លួនក៏បានចេញទៅផ្ទះដែរ ពេលពួកខ្លួនធ្វើដំណើរពីរោងកាហ្វេក្មួយប្រុសខ្លួនឈ្មោះ ក្រេង តេង ជាអ្នកឌុបខ្លួននិងឈ្មោះ ចន្ទី ពេលពួកខ្លួនធ្វើដំណើរបានបន្តិចស្រាប់តែមានមនុស្សលបវាយពួកខ្លួន ពេលនោះគេវាយត្រូវខ្លួន១ដំបងចំក្បាលបណ្ដាលឲ្យខ្លួនធ្លាក់ពីលើម៉ូតូដួលសន្លប់បាត់ស្មារតីនៅកន្លែងកើតហេតុតែម្ដង។

៥. តាមរបាយការណ៍សរុបលេខ ៦១ របក ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ របស់អធិការដ្ឋាននគរបាលស្រុកកោះធំ បានបញ្ជាក់ថា នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ ក្នុងភូមិចំការដូង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្ដាល ពិតជាមានឈ្មោះ [redacted] គឹមឡេង និងបក្សពួកឈ្មោះ [redacted] សុខនី, ឈ្មោះ [redacted] ឌីណា, ឈ្មោះ [redacted] លាងហេង មានការពាក់ព័ន្ធក្នុងអំពើហិង្សាដោយចេតនាទៅលើឈ្មោះ ស្រេង ខ្លឹង ប្រាកដមែន ។

៦. តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋាន: តាមការសួរដេញដោលឃើញថាមិនមានភស្តុតាងដាក់បន្ទុកណាមួយលើជនជាប់ចោទឈ្មោះ [redacted] លាងហេង ក្នុងការប្រព្រឹត្តបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចំការដូង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ ២០១២ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌនោះទេ ។ ដូច្នេះ ក្នុងនាមជាតំណាងអយ្យការស្នើសុំឲ្យតុលាការពិចារណា និងសម្រេចឲ្យជនជាប់ចោទឈ្មោះ [redacted] លាងហេង បានរួចខ្លួនពីបទចោទប្រកាន់ បទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចំការដូង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្ដាល កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ តាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌផង ។

៧. តាមការសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ: តាមអង្គហេតុខាងលើ កូនក្ដីរបស់ខ្លួនឈ្មោះ [redacted] លាងហេង ពុំបានប្រព្រឹត្តអំពើហិង្សាទៅលើ



Scanned with CamScanner

ជនរងគ្រោះឈ្មោះ [redacted] ខ្លឹង នោះទេ ។ ចំពោះអង្គហេតុដែលចោទប្រកាន់ដោយតំណាងអយ្យការ ការឆ្លើយបញ្ជាក់របស់ជនរងគ្រោះ ឈ្មោះ [illegible] ខ្លឹង និងការឆ្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] តេង, ឈ្មោះ [redacted] ចន្ទី និងឈ្មោះ [redacted] សុខធី អាចបញ្ជាក់បានថា: កូនក្តីរបស់ខ្លួនឈ្មោះ [redacted] លាងហេង ពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ព្រោះពុំមានសាក្សីណាមួយ មកឆ្លើយបញ្ជាក់ឲ្យបានច្បាស់លាស់ថាកូនក្តីខ្លួននៅក្នុងហេតុការណ៍ដែលបានកើតឡើង ឬជាអ្នកប្រព្រឹត្តនោះឡើយ ។ ដូចអង្គហេតុបានបញ្ជាក់តាមរយៈរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ដីកាសន្និដ្ឋានស្ថាពរ, ដីកាដំណោះស្រាយ, ការរៀបរាប់របស់ជនរងគ្រោះ និងការឆ្លើយបំភ្លឺរបស់សាក្សី គឺពុំបានបញ្ជាក់ឲ្យច្បាស់ពីការប្រព្រឹត្តបទល្មើសរបស់កូនក្តីខ្លួនឡើយ ដែលនាំឲ្យមានវិមតិសង្ស័យលើកូនក្តីខ្លួន និងខ្វះធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ (ធាតុសត្យានុម័ត និងធាតុអវត្តនោច័ត)ផងដែរ ។ ផ្អែកតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ជនជាប់ចោទ ។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ [redacted] លាងហេង សូមសំណូមពរឲ្យតុលាការមេត្តាពិចារណា និងសម្រេច ឲ្យកូនក្តីរួចខ្លួនពីការចោទប្រកាន់ ពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ នៅចំណុចភូមិចំការដូង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល និងបញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ១៨៥ ដក.បចខ ចុះថ្ងៃទី០៦ ខែមិនា ឆ្នាំ២០១៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល។

៨. ផ្អែកតាមសំអាងហេតុខាងលើ ឃើញថាពុំមានភស្តុតាងច្បាស់លាស់បញ្ជាក់ថាជនជាប់ចោទឈ្មោះ លន លាងហេង មានកំហុសពាក់ព័ន្ធនឹងបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចំការដូង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ តាមមាត្រា ៣៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីតុលាការសម្រេចតម្កល់សាលក្រមលេខ ០២៩ "ណ" ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការ ប៉ុន្តែកែប្រែត្រង់ចំណុចខ្លះ ។

**ហេតុដូច្នេះ-តុលាការ**

**សម្រេច**

១_តម្កល់សាលក្រមលេខ ០២៩ "ណ" ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការ ។

២_ កែប្រែត្រង់ចំណុចទី១.១ នៃសាលក្រមលេខ ០២៩ "ណ" ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តកណ្តាល ដោយឲ្យជនជាប់ចោទឈ្មោះ លន លាងហេង រួចខ្លួនពីបទចោទ បទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិចំការដូង ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ តាមមាត្រា ៣៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣_ បញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ១៨៥ ដកបចខ ចុះថ្ងៃទី០៦ ខែមិនា ឆ្នាំ២០១៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ។

សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ ឈ្មោះ លន លាងហេង ប៉ុន្តែកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ស្រេង សារុំ និងជនរងគ្រោះ ឈ្មោះ ស្រេង ខ្លឹង ។

៤_ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ និងឯកភាព

**តំណាងអយ្យការ**

[redacted]

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner